អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី៧ ខែមីនា ឆ្នាំ ២០១៤

# សេចក្តីប្រកាសព័ត៌មាន

## ប្រទេសកាតាផ្តល់វិភាគទានចំនួន ២០ ០០០ ដុល្លារអាមេរិកដល់ អ.វ.ត.ក

ប្រទេសកាតាបានប្រកាសផ្តល់វិភាគទានជាទឹកប្រាក់ចំនួន ២០ ០០០ ដុល្លារអាមេរិកដល់ភាគីជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ នៅក្នុងលិខិតដែលបានប្រកាសពីវិភាគទានថ្មីនេះ ស្ថានបេសកកម្មអចិន្ត្រៃយ៍នៃប្រទេសកាតាប្រចាំអង្គការសហប្រជាជាតិ បានលើកឡើងថា ការផ្តល់វិភាគទាននេះធ្វើឡើងជាការឆ្លើយតបទៅនឹងសេចក្តីអំពាវនាវរបស់ឯកឧត្តម បាន គីមូន អគ្គលេខាធិការ អ.ស.ប ដល់រដ្ឋសមាជិកទាំងអស់សូមជួយផ្តល់នូវការគាំទ្រផ្នែកហិរញ្ញវត្ថុជាបន្ទាន់ ដល់ អ.វ.ត.ក។

ឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី និងលោក ឃ្នុត រ៉ូហ្សិនហាក អនុប្រធានការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក បានមានប្រសាសន៍ថា៖“ក្នុងកាលៈទេសៈប្រឈមសម្រាប់ភាគីជាតិនៃ អ.វ.ត.ក យើងខ្ញុំមានក្តីសោមនស្សរីករាយ ស្វាគមន៍រដ្ឋកាតា ក្នុងនាមជាប្រទេសម្ចាស់ជំនួយថ្មីរបស់ អ.វ.ត.ក ហើយយើងខ្ញុំសូមសម្តែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះប្រទេសកាតាដែលបានផ្តល់វិភាគទាននេះ។ យើងខ្ញុំរង់ចាំការបន្តគាំទ្រពីប្រទេសកាតា និងពីប្រទេសម្ចាស់ជំនួយដទៃទៀត ក្នុងដំណើរស្វែងរកយុត្តិធម៌ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ”។

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទចល័ត: +៨៥៥ (០) ១២ ៤៨៨ ០២៣
សារអេឡិកត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទចល័ត: +៨៥៥ (០) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh